ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ ៧៦១ /របប.សដណ
១៩

# សេចក្តីជូនដំណឹង
## ស្តីពី
## ការស្នើសុំការអនុញ្ញាតសាងសង់ និងជួសជុលសំណង់របស់ប្រជាពលរដ្ឋ នៅក្នុងតំបន់រមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា សូមជម្រាបជូនដំណឹងដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី និងសាធារណជនទាំងអស់ ជាពិសេសប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់រមណីយដ្ឋានអង្គរទាំងអស់បានជ្រាបថា៖ តំបន់រមណីយដ្ឋានអង្គរគឺជារមណីយដ្ឋាននៃបេតិកភណ្ឌពិភពលោក ដែលសម្បូរទៅដោយប្រាង្គប្រាសាទដ៏ល្បីល្បាញជាច្រើន ជាពិសេសប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន ដែលជាទីគោរពសក្ការៈដ៏ស័ក្តិសិទ្ធិ និងជាដួងព្រលឹងរបស់ជាតិខ្មែរទាំងមូល ព្រមទាំងបុរាណដ្ឋាន និងវត្ថុបុរាណជាច្រើនទៀតដែលកប់នៅក្នុងដី។ ដូចនេះ ដើម្បីថែរក្សាការពារនូវតម្លៃដ៏វិសេសវិសាលនៃមរតកដូនតាខ្មែរយើងឱ្យបានគង់វង្សយូរអង្វែង រាល់ការជួសជុលផ្ទះចាស់ ការរុះរើផ្ទះចាស់សង់ថ្មី ការជួសជុលសំណង់តូចតាច ការធ្វើរបងដី...។ល។ ក្នុងតំបន់រមណីយដ្ឋានអង្គរ ត្រូវមានលិខិតអនុញ្ញាតជាមុនពីអាជ្ញាធរជាតិអប្សរា។

ចំពោះការដាក់ពាក្យស្នើសុំសាងសង់ ជួសជុលសំណង់គ្រប់ប្រភេទក្នុងតំបន់រមណីយដ្ឋានអង្គរ បងប្អូនប្រជាពលរដ្ឋអាចមកដាក់ពាក្យស្នើសុំដូចខាងក្រោម៖

- នៅមជ្ឈមណ្ឌលសេវាកម្មច្រកចេញចូលតែមួយនៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា
- តាមរយៈក្រុមការងារអាជ្ញាធរជាតិអប្សរាដែលប្រចាំការនៅតាមក្រុង/ស្រុកពាក់ព័ន្ធ
- តាមរយៈក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរា ដែលចុះទៅតាមគោលដៅក្រុង/ស្រុកទាំង៥ (ចំពោះការស្នើសុំជួសជុលតូចតាច)។

ឆ្លៀតឱកាសនេះ អាជ្ញាធរជាតិអប្សរាសូមបញ្ជាក់ជូនបងប្អូនប្រជាពលរដ្ឋមេត្តាជ្រាបផងដែរថា រាល់ការស្នើសុំសាងសង់ ជួសជុលសំណង់គ្រប់ប្រភេទក្នុងតំបន់រមណីយដ្ឋានអង្គរ មិនតម្រូវឱ្យបង់ថ្លៃសេវាអ្វីឡើយ។ ហេតុនេះប្រសិនបើមានមន្ត្រី ឬបុគ្គលណាម្នាក់ ទៅគំរាមទាមទារឱ្យបង់ប្រាក់ថ្លៃសេវា ឬទាមទារប្រាក់ជាថ្នូរនឹងការបិទបាំងឱ្យសាងសង់ ជួសជុលគ្រប់ប្រភេទ ដោយល្មើសច្បាប់ សូមបងប្អូនប្រជាពលរដ្ឋ មេត្តាជួយផ្តល់ព័ត៌មាន ឬភស្តុតាងផ្សេងៗ ដូចជាការថតសំឡេង រូបភាព ...។ល។ របស់មន្ត្រី បុគ្គលខិលខូចទាំងនោះ ផ្ញើជូនមកអាជ្ញាធរជាតិអប្សរា ដើម្បីជាភស្តុតាងសម្រាប់ចាត់ការទៅតាមនីតិវិធីច្បាប់ជាធរមាន។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោកជំទាវ លោក លោកស្រី និងសាធារណជនទាំងអស់ ជាពិសេសប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់រមណីយដ្ឋានអង្គរទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ អង្គារ ១២ កើត ខែ ភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
សៀមរាប ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៩

**អគ្គនាយក**

**ហង់ ពៅ**

**ចម្លងជូន៖**
- ខុទ្ទកាល័យក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- រដ្ឋបាលខេត្តសៀមរាប
- គ្រប់មន្ទីរជុំវិញខេត្ត
- សាលាក្រុង/ស្រុកទាំង៥
- ឃុំ/សង្កាត់ពាក់ព័ន្ធ

«ដើម្បីជូនជ្រាបជាព័ត៌មាន»

- ក្រុមការងារអ្នកច្បាប់ជួយអាជ្ញាធរជាតិអប្សរា
- គ្រប់នាយកដ្ឋាន-អង្គភាពចំណុះអាជ្ញាធរអប្សរា
- អង្គភាពនគរបាលការពារបេតិកភណ្ឌប្រចាំខេត្តសៀមរាប
- អង្គភាពនគរបាលទេសចរណ៍ប្រចាំខេត្តសៀមរាប

«ដើម្បីជ្រាប»

- ឯកសារ-កាលប្បវត្តិ

ភ្នំពេញ:
អគារលេខ៨៤ ផ្លូវលេខ២១៤ សង្កាត់បឹងរាំង ខណ្ឌដូនពេញ
ទូរស័ព្ទ/ទូរសារ៖ ០២៣ ២១៥ ៧៧១/ ០២៣ ២១៥ ៧៧៦

អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Email: info@apsaraauthority.gov.kh
Website: apsaraauthority.gov.kh

សៀមរាប:
ភូមិបង្គោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
ទូរស័ព្ទ/ទូរសារ៖ ០៦៣ ៧៦៥ ៥៧៧/ ០៦៣ ៧៦៥ ៥៧៦